# អាណាជាអ្នកបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា២ធ្នូ១៩៧៨

## ឬ រណសិរ្សសាមគ្គីម៉ឺនឆ្នាំដាក់ប្រទេសខ្មែរក្រោមនឹមរបស់យួន

កម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម នឹង ប្រទេសយួនកុម្មុយនិស្ត មានការទំនាស់គ្នាដោយផ្ទុះអាវុធជារឿយៗ នៅតាមបណ្តោយព្រំដែនតាំងពីខេត្តរតនៈគិរីហ្វេតដល់ខេត្តកំពតដោយមិនចុះសំរុងនឹងគ្នាក្នុងការកំណត់ព្រំដែន រវាងខ្មែរនឹងយួនតាំងពីឆ្នាំ១៩៧៦មក។ រឿងទំនាស់ព្រំដែនរវាងខ្មែរ នឹង យួននេះ បណ្តាលឲ្យខ្មែរក្រហម ផ្តាច់ទំនាក់ទំនងចំណងផ្លូវទូតរវាងខ្មែរ នឹង យួន តាំងពីចុងឆ្នាំ១៩៧៦មកម្លេះ ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានសម្រេចចិត្តបញ្ជូនទ័ពខ្មែរក្រហមនៅភូមិភាគបូព៌ាដែលឈរជើងនៅតំបន់ស្រុកមេមត់ចំនួនប្រាំមួយពាន់នាក់ (៦,០០០ នាក់) ឲ្យចូលទៅវាតត្បាតវាយកំទេចកាប់សម្លាប់យួននៅតាមព្រំដែនខ្មែរយួនក្នុងខេត្តតៃនិញ ឬ ខេត្តរោងដំរីកម្ពុជាក្រោម ទល់មុខនឹងស្រុកមេមត់ក្នុងខេត្តកំពង់ចាម ។

ទ័ពខ្មែរក្រហមចំនួន ៦,០០០ នាក់នេះនៅក្រោមបញ្ជាការរបស់មេទ័ពខ្មែរក្រហមឈ្មោះអា ហេង សំរិន ។ កាលនោះអាហេង សំរិន ជាមេទ័ពខ្មែរក្រហមយ៉ាងប្លូរផ្តាច់ប្រឆាំងដាច់ខាតប្រឆាំងស្លាប់រស់ជាមួយយួន ។ ក្នុងជួរមេទ័ពខ្មែរក្រហមទាំងអស់ដែលចូលទៅលុកលុយព្រំដែនយួននោះមានឈ្មោះអាក្បត់ជាតិ ហ៊ុន សែន ជាប្រធានកងអនុសេនាធំ (**commandant de compagnie)** ត្រួតទាហានខ្មែរក្រហមប្រហែលចំនួនមិនលើសពី១០០នាក់ឡើយ ។ កាលនោះអាក្បត់ជាតិខ្មែរឈ្មោះហ៊ុន សែននេះមានឈ្មោះអាហ៊ុន ណាល់ជាឈ្មោះកំណើតដែលឈ្មោះអាហ៊ុន នាង ជាឪពុកវាដាក់ឈ្មោះឲ្យវាតាំងតែវាបានកើតមក ។ អាក្បត់ជាតិខ្មែរហ៊ុន ណាល់នេះ ក៏ប្រឆាំងដាច់ខាតនឹងយួនដែរ។ ពេលចូលទៅវាយយួននៅតាមទល់ដែននេះ ទ័ពខ្មែរក្រហមទាំងអស់នោះ គ្មានកងកាំភ្លើងធំ គ្មានកងរថក្រោះ គ្មានកងយន្តហោះចំបាំង ចាំជួយអន្តរាគមន៍ជួយគាំពារទេ ទាហានខ្មែរក្រហមម្នាក់ៗ មានតែកាំភ្លើងដែផ្ទាល់ខ្លួនក្នុងម្នាក់ៗ មួយដើម បេ៤០ខ្លះ កាំភ្លើងយន្តលេខ៣០ ខ្លះ កាំភ្លើងយន្តលេខ១២-៧ ខ្លះ គ្រាប់រំសេវ នឹងស្បៀងអាហារខ្លះ ។ ឯកាំភ្លើងធំជាងគេ សម្រាប់ជួយការពារទ័ពមានតែកាំភ្លើងដែលខ្មែរក្រហមឲ្យឈ្មោះថា បេកា (B.K,**Canon 75 sans recule portatif )** មានប្រហែលពីរ ឬ បីដើម ។ ខ្មែរក្រហមទាំអស់នេះ ក្រោមបញ្ជាការរបស់អា ហេង សំរិន កាចសាហាវព្រៃផ្សៃណាស់ សម្លាប់យួនមិនរើសមុខ ក្មេងចាស់ ប្រុស-ស្រី ដុតកំទេចផ្ទះយួន បំផ្លាញទ្រព្យសម្បត្តិយួនគ្មានសល់ឡើយ ។ ពេលនោះទាហានយួនបាញ់តទល់រប៉េះរប៉ស់ជាមួយខ្មែរក្រហម ហើយចេះតែដកថយទៅក្នុងរហូត ។ ទ័ពខ្មែរក្រហមយល់ថាខ្លួនមានជោគជ័យលើយួនហើយក៏កាន់តែវាយសម្រុកខ្លាំងទៅមុខឥតរុញរាឡើយ លុះទ័ពខ្មែរក្រហមចូលទៅឆ្ងាយពីព្រំដែនហើយ ទាហានយួនក៏ពាត់ពីខាងក្រោយ ធ្វើឲ្យទ័ពខ្មែរក្រហមបាក់ទ័ពងាប់គរជើង ងាប់អស់ប្រហែលជិត៣,០០០ក្បាល ។ នៅសល់ប្រហែលជាង៣,០០០ក្បាលរត់ប្រាសមកស្រុកខ្មែរវិញសឹងតែមិនទាន់ព្រោះទាហានយួនតាមបាញ់ប្រហារពីក្រោយ ។ អាប៉ុល ពត បានទទួលតំណឹងអាក្រក់ថាពួកអាហេង សំរិន បាក់ទ័ពចាញ់យួនហើយ។ អាប៉ុល ពត ក៏បានចោទប្រកាន់ទៅលើទ័ពអាហេង សំរិន ថាពួកអាទ័ពនៅបូព៌ាចូលដៃចូលជើងជាមួយនឹងយួនហើយ ទើបវាវាយចាញ់យួន ។ អាប៉ុល ពត ក៏បានបញ្ជាទៅអាកែ ពក មេទ័ពនៅភូមិភាគឧត្តរ ឲ្យទៅចាំទទួលទ័ពអាហេង សំរិន នឹងគ្រាប់កាំភ្លើងនៅតាមព្រំដែន ។ ទ័ពអាហេង សំរិន ត្រូវងាប់ទៀត នៅសល់ប្រដែលជាង២,០០០ក្បាល រត់ប្រាសអាយុទៅលាក់

ខ្លួនពួនអាត្មាឲ្យផុតពីមរណៈនៅក្នុងព្រៃ នៅស្រុកស្នួលក្នុងខេត្តក្រចេះ ។ ពេលនោះទ័ពខ្មែរក្រហមរបស់អាកែ ពក នឹង ទ័ពអាប៉ុល ពត ក៏មិនមានលទ្ធភាពដេញតាមទ័ពអាហេង សំរិន នៅស្រុកស្នួលដែរ ។ ពេលនោះដោយក្ដីអស់សង្ឃឹមអាជា ស៊ីម ក៏ប្រថុយនាំទ័ពប្រហែល៣០០ក្បាលទៅសុំយួនជ្រកកោនឲ្យផុតពីងាប់តែហោងពីការតាមវាយប្រហាររបស់អាកែ ពក ។ យួនស្ទើរតែទប់ចិត្តមិនបាន ពេលដែលបានឃើញអាជា ស៊ីម នាំទ័ពទៅសុំជ្រកកោន ។ អាយួនវាចង់តែសម្លាប់អាជា ស៊ីមចោលតែម្ដង តែអាយួនវានឹកឃើញថាៈ វាកំពុងតែដើររកអុស ឥឡូវប៉ះឈើងាប់ហើយ វាត្រូវតែយកឈើងាប់នេះមកធ្វើជាអុសរបស់វា សំតាមគោលបំណងវាដែល ខ្មោចអាហូ ជីមីញ មានគោលបំណងធ្វើបណ្ដាំឲ្យកូនចៅយួនជំនាន់ក្រោយៗ ទោះរង់ចាំអស់រយៈពេលប៉ុន្មានឆ្នាំក៏ដោយ ត្រូវតែរង់ចាំយកប្រទេសខ្មែរឲ្យបាន ហើយបញ្ចូលទៅក្នុងសហពន្ធ័ឥណ្ឌូចិន ដែលមានអាយួនជាអ្នកត្រួតត្រា ដែលជាបណ្ដាំរបស់អាហូ ជីមីញ តាំងតែពីឆ្នាំ១៩៣០ មកម្លេះ ។

ក្រោយពីការយល់ព្រមឲ្យអាជា ស៊ីម ជ្រកកោនរួចមក អាយួនក៏មិនទាន់ទុកចិត្តអាជា ស៊ីមទាំងស្រុងដែរ ។ អាយួនបានបញ្ជាទៅអាជា ស៊ីម ឲ្យចូលមកស្រុកស្នួលវិញដើម្បីឲ្យអាជា ស៊ីម ប្រមូលមេទ័ពទាំងអស់ដែលនៅសល់ពីងាប់ចូលទៅស្រុកយួន នៅក្នុងនោះមាន អាហេង សំរិន នឹងអាហ៊ុន សែន ឬ អាហ៊ុន ណាល់ដែរ។ អាយួនក៏បានចាប់មេទ័ពខ្មែរក្រហមទាំងអស់នោះយកទៅដាក់គុកសិនដើម្បីស៊ើបរកការពិត ។

ដោយមានអំណោយផល គឺមានទ័ពខ្មែរក្រហមប្រហែលជាងពីរពាន់ក្បាលនៅឯស្រុកស្នួលហើយ អាយួនក៏វាបង្កើតរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី ២ ខែធ្នូ ១៩៧៨ ដោយចាត់តាំង ប៉ែន សុវណ្ណ ជានាយទាហានយួនពាក់សក្តិ២ មានដើមកំណើតជាខ្មែរយៀកមិញ ដែលបានចូលធ្វើជាកងទ័ពខ្មែរយៀកមិញតាំងតែពីគុមារភាព ហើយបានទៅបំរើយួនកុម្មុយនិស្តនៅឯហាណូយតាំតែពីឆ្នាំ១៩៥៤ ឲ្យធ្វើជាប្រធានរបស់ដែលហៅថា

# រណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា២ធ្នូ១៩៧៨ ឬ

# រណៈសិរ្សសាមគ្គីម៉ឺនឆ្នាំដាក់ប្រទេសខ្មែរក្រោមនឹមរបស់យួន

ឯអាជា ស៊ីម, អាហេង សំរិន, អាហ៊ុន សែន នឹង មេទ័ពខ្មែរក្រហមឯទៀតៗ ដែលត្រូវយួនយកទៅញាត់គុក ត្រូវបានប៉ែន សុវណ្ណ សុំឲ្យអាយួនដោះលែងពីគុក ។ ដើម្បីសុំឲ្យអាយួនដោះលែងអាជា ស៊ីម, អាហេង សំរិន, អាហ៊ុន សែន ៖ ប៉ែន សុវណ្ណ បានពន្យល់អាយួនថា បើយើងមុតបន្លា យើងត្រូវរកបន្លាធ្វើជាម្ជុលដើម្បីជោះយកបន្លានោះចេញ យ៉ាងណាមិញបើយើងវាយខ្មែរក្រហម យើងត្រូវតែប្រើខ្មែរក្រហមឲ្យវាជួយច្បាំងយើង ចំត្រូវចំណុចនេះអាយួនក៏សុខចិត្តដោះលែងអាជា ស៊ីម, អាហេង សំរិន, អាហ៊ុន សែន ឲ្យចេញពីគុក ឲ្យជួយដេញខ្មែរក្រហមពីប្រទេសខ្មែរដោយមានទ័ពអាយួនកុម្មុយនិស្តជាងម្ភៃម៉ឺនក្បាលចូលមកវាយយកប្រទេសខ្មែរដាក់ជាចំណុះរបស់វាដោយយកលេះថាមកស្រោចស្រង់ខ្មែរឲ្យរួចពីការសម្លាប់ ។ ដូច្នេះសូមកូនខ្មែរទាំងអស់ទាំងនៅក្នុងស្រុក ទាំងនៅក្រៅប្រទេសខ្មែរ សូមកុំជឿរឲ្យសោះពាក្យដែលអាហ៊ុន សែន វាបានស្រែកស្ទើរយាស់មាត់ថាវា (អាហ៊ុន សែន) ជាបិតាស្ថាបនិក ឬ ប្រធានបង្កើតរបស់បំផ្លាញជាតិខ្មែរ ដែលហៅថា ៖ **រណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា២ធ្នូ១៩៧៨ ស្អីគេនោះឲ្យសោះ ។**

**ឯ ប៉ែន សុវណ្ណ ក៏មិនមែនជាអ្នកបង្កើត ឬ ជាបិតា រណសិរ្សចង្រៃនេះដែរ គឺអាយួន ដែលជាអ្នកបង្កើតរណសិរ្សដ៏ចង្រៃអពមង្គលនេះដើម្បីវាយយកប្រទេសខ្មែរឲ្យបានតាមពាក្យបណ្តាំរបស់អាហូ ជីមីញ ពីឆ្នាំ១៩៣០ ។**

តាមការសង្កេតនឹងការឈ្លាសវៃរបស់អាយួន នឹង ការរឹងរូសរបស់ប៉ែន សុវណ្ណ មិនធ្វើអ្វីៗទៅតាមបញ្ជារបស់អាយួនឲ្យបាន១០០% អាយួនក៏ចាប់ប៉ែន សុវណ្ណយកទៅញាត់គុកងងឹតឯហាណូយទៅ ។ ឯអាហ៊ុន សែនវិញ ភ័យញ័រកន្ទុយ ខ្វៃទៅគ្របពងក្តមិនហ៊ានប្រកែកនឹងយួនឡើយព្រោះយួនបានជួយសង្គ្រោះវាឲ្យចាកផុតពីងាប់តែហោង ពីកណ្តាប់ដៃនៃមច្ចុរាជ ឈ្មោះកែ ពក ។ ហេតុដូច្នេះហើយបានជាអាហ៊ុន សែន វាលើកដំកើងអាយួនទុកជាម៉ែឪទីពីររបស់វា ទោះអាយួនវាយកប្រទេសខ្មែរ ទោះអាយួនវាសម្លាប់ជាតិខ្មែរ ទោះអាយួនវារំលោភបំពានបង្ខិតព្រំដែនខ្មែររហូតមកដល់ត្រើយខាងកើតទន្លេមេកុងក៏ដោយ ក៏អាក្បត់ជាតិខ្មែរឈ្មោះអាហ៊ុន សែន យល់ព្រមទៅតាមសំណើររបស់អាយួនទាំងអស់មិនហ៊ានប្រកែកឡើយ ព្រោះអាយួនបានតែងតាំងវាឲ្យឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអាស្រ័យយួនកុម្មុយនិស្ត ដែលមានឈ្មោះអាមោឃៈ មានឈ្មោះអានរោត្តម សីហមុនី ជាស្តេចម៉ិមហាធម្មោឃៈរាជា ជាត្រាកៅស៊ូរ សម្រាប់ធ្វើអ្វីៗឲ្យបានស្រប ទៅតាមគោលបំណងរបស់អាក្បត់ជាតិ អាតិរិច្ឆាន ហ៊ុន សែន បាន១០០% មិនអាចឲ្យមានខ្វះចន្លោះត្រង់ចំណុចណាឡើយ ។ សូមបញ្ជាក់ថាអាយួនវាមានគោលបំណងបង្ខិតព្រំដែនខ្មែរឲ្យបានជាស្ថាពរដល់ព្រំដែនប្រទេសសៀមប៉ែកខាងកើតទើបអាយួនវាស្ងប់ចិត្តមួយរយៈ ។ ឯអាកញ្ចាស់ឈ្មោះនរោត្តម សីហនុវិញ អាក្បត់ជាតិខ្មែររូបនេះវាបានគាំទ្រអាយួនឲ្យយកប្រទេសខ្មែរតាំងតែពីឆ្នាំ១៩៤១មកម្ល៉េះ ។ ឥឡូវនេះអាក្បត់ជាតិខ្មែរអានរោត្តម សីហនុនេះ វាបានប្រកាសថាវានឹងគាំទ្រអាហ៊ុន សែន 100% រហូតដល់ថ្ងៃវាងាប់តែហោង ដើម្បីអនុញ្ញាតឲ្យយួនបញ្ចូលប្រទេសខ្មែរឲ្យបានឆាប់ទៅក្នុងសហពន្ធ័ឥណ្ឌូចិន ទៅតាមគំរោងរបស់អាហូ ជីមីញ ពីឆ្នាំ១៩៣០ ។

សូមកូនខ្មែរដែលជាសៅ្មរាំង ឬ ជាចៃរាំងដែលធ្លាប់តែដើរជើងទា វារជើងបួន យកកន្ទោរពាក់ធ្វើជាមួកឈប់ហិតគំរង់ផោមអាស្តេចម៉ិថាជាក្លិនទឹកអប់តទៅទៀតទៅ ហើយចូលមករួបរួមជាមួយកូនខ្មែរអ្នកស្នេហាជាតិដើម្បីរំដោះជាតិមាតុភូមិពីកណ្តាប់ដៃអាយួន ពីកណ្តាប់ដៃពពួកអាកញ្ជះយួន មានអាជា ស៊ីម អាហេង សំរិន អាហ៊ុន សែន នឹងពីកណ្តាប់ដៃអានរោត្តម សីហនុ នឹង អានរោត្តម សីហមុនី ឲ្យ បានទាន់ពេលវេលា ។ សូមលោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី ព្រមទាំងសមាជិកគណបក្សសម រង្ស៊ី ទាំងអស់ នឹង លោក កឹម សុខា ប្រធានគណបក្សកឹម សុខា ព្រមទាំងសមាជិកគណបក្សកឹម សុខាទាំងអស់ ឈប់ខ្វែងគំនិតនឹងគ្នា ឈប់ប្រកាន់បក្សពួក សូមលះបង់មហិច្ឆតាលោភលន់រកប្រយោជន៏ផ្ទាល់ខ្លួនចោលចេញឲ្យអស់ពីក្នុងខ្លួន លើកយកបញ្ហាការស្លាប់រស់ប្រទេសខ្មែរ មកដាក់លើតុមូល ហើយពិភិក្សាគ្នារករូបមន្តមួយជាកណ្តាលដើម្បីច្របាច់បញ្ចូលគណបក្សសម រង្ស៊ី នឹង គណបក្សកឹម សុខា ឲ្យទៅជាគណបក្សស្រោចស្រង់ប្រទេសខ្មែរឲ្យទាន់ពេលវេលា ដើម្បីប្រឆាំងតទល់នឹងអាឆ្កែបំរើយួនគឺ អាជា ស៊ីម, អាហេង សំរិន, អាហ៊ុន សែន នៅពេលបោះឆ្នោតនាឆ្នាំ២០១៣ ខាងមុខនេះ ។ បើគណបក្សសម រង្ស៊ី នឹង គណបក្សកឹម សុខា ចាញ់ឆ្នោតនៅឆ្នាំ២០១៣ហើយ សូមលោកសម រង្ស៊ី នឹង លោកកឹម សុខា កុំសង្ឃឹមថាលោកទាំងពីរនាក់នឹង

មានឱកាសទៅអនាគតឲ្យសោះ ។ លោកទាំងពីរនាក់នឹងក្លាយខ្លួនទៅជាឧបករណ៏ ឬ ទាសកររសម្រាប់ទប់ជើងគ្រែឲ្យអាក្បត់ជាតិខ្មែរឈ្មោះអាហ៊ុន សែន ដោយមានអានរោត្តម រណ្ណរិត, ញឹក ប៊ុនឆៃ, កែវ ពុតរស្មី ចូលរួមជាមួយគ្នាមិនខានឡើយ ។ លោកសម រង្ស៊ី នឹង លោកកឹម សុខា នឹងក្លាយខ្លួនរួមគ្នាទាំងពីរនាក់ទៅជាប្រធានគណបក្សប្រឆាំង សម្រាប់តែប្រថាប់ត្រាទៅតាមលិទ្ធិប្រជាធិបតេយ្យអាស្រ័យយួនកុម្មុយនិស្ត ដើម្បីឲ្យអាហ៊ុន សែន មេក្បត់ជាតិខ្មែរ ក្លាយខ្លួនទៅធ្វើជានាយករដ្ឋមន្ត្រីរៀងរហូតទៅតាមចំណង់ចិត្តរបស់វានៅក្នុងផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាអាស្រ័យកុម្មុយនិស្តយួនហាណូយមិនអាចប្រកែកបានឡើយ ។

ភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០១១

ខែម ខៀវ